ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ : ១៥៧
ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៨

----------

សាលដីកា
លេខ : ២១២
ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ :

១_ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២_លោក ខែប៉ន ស៊ុន ជាចៅក្រមរាយការណ៍
៣_លោក រៀល មួន ជាចៅក្រម
៤_លោក ជីវ កេង ជាចៅក្រម
៥_លោក ស៊ុន ឌឹម ជាចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៨៥ ចុះថ្ងៃទី ១០.៣.៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៣៨ ចុះថ្ងៃទី ២៤.១២.៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សុខ ទៀង ភេទស្រី អាយុ ៤៥ឆ្នាំ សញ្ជាតិ កម្ពុជា របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥៤៧អឺ០ ផ្លូវលេខ ១២៨ ក្រុមទី ២៤ សង្កាត់ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ "តំណាងអោយប្តីឈ្មោះ សុខ ផេង"

និង ចុងបណ្តឹងសាទុក្ខឈ្មោះ នួន ថារ៉ា ភេទប្រុស អាយុ ៣១ឆ្នាំ សញ្ជាតិ កម្ពុជា របររកស៊ី ក្រសួងឧស្សាហកម្ម ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៥៤៧អ៊ី១ ផ្លូវលេខ១២៨ ក្រុមទី ២៤ សង្កាត់ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ "តំណាងអោយឪពុកឈ្មោះ ថែម ថាល់" ។

កម្មវត្ថុបណ្តឹង : សុំអោយបិទជញ្ជាំងផ្ទះដូចដើមវិញ

តាមបណ្តឹងសាទុក្ខលេខ ៨៧ ចុះថ្ងៃទី ៣០.៤.៩៨ របស់ឈ្មោះ សុខ ទៀង ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ៨៥ ចុះថ្ងៃទី ១០.៣.៩៨ របស់សាលាឧទ្ធរណ៍ លើចំនុច នៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៥៧ ចុះថ្ងៃទី ០៣.៦.៩៨ របស់

តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ០៦.៨.៩៧ របស់ឈ្មោះ ថែម ថាវ ប្ដឹងពីលោក សុខ ផេង អោយបិទជញ្ជាំងផ្លូវដើរវិញ ដោយសំអាងហេតុថា កាលពីមុនឆ្នាំ ១៩៩២ នៅពីក្រោយជណ្ដើរផ្ទះខ្លួន មានឈរដីទំនេរទំហំ៦,៥ម$^{2}$ គឺទទឹង ១,៣ម បណ្ដោយ ៥ម ដែលជាកម្មសិទ្ធិរបស់ខ្លួន សំរាប់ចេញចូលជួលជុលលូ ។ នៅចុងឆ្នាំ ១៩៩២ ឈ្មោះ សុខ ផេង សុំខ្លួនខាងជញ្ជាំងផ្ទះគាត់ពង្រីកទទឹងផ្ទះ លើដីទំនេរនេះ ដោយសន្យាអោយខ្លួនដាក់ម៉ូទ័រ នៅផ្ទះគាត់មិនយកឈ្នួល តែគាត់ទារលុយម៉ូទ័រពីខ្លួន រហូតដល់ថ្ងៃទី ២៥.៧.៩៧ ក៏ខឹងខ្លួន មិនអោយដីកជណ្ដើរផ្ទះខ្លួន ដើម្បីដាក់ក្នុងទីរបន្ថែមមួយទៀត រួចក៏ទារថ្លៃដាក់ម៉ូទ័រតម្លើងថ្លៃ ដែលផ្ទុយពីពាក្យសន្យា ។

បានឃើញសាលក្រមលេខ ១២៣ "ក" ចុះថ្ងៃទី ១៥.១០.៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ១៩៩៧ របស់ដើមចោទ ឈ្មោះ ថែម ថាវ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលស្គាល់ការផ្ទេរសិទ្ធិពីឈ្មោះ ថែម ថាវ អោយទៅឈ្មោះ នួនថាវ៉ា ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់ការផ្ទេរសិទ្ធិពីឈ្មោះ សុខ ផេង អោយទៅឈ្មោះសុខ ទៀង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បង្គាប់អោយនារី សុខ ទៀង រុះរើជញ្ជាំងចេញពីដីក្រោយជណ្ដើរ ទំហំ ១០ម គុណ ១,៣ម ស្ថិតនៅផ្ទះលេខ ៥៤៧អឺ០ ក្រុមទី ២៤ ផ្លូវលេខ ១២៨ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ និង ទុកដីទំហំ ១០ម គុណ ១,៣ម នេះ ប្រើប្រាស់ជាសាធារណៈ ដូចដើមវិញ ។

៥-បង្គាប់អោយនារី សុខ ទៀង បង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីការពិបប្រាក់ ២០០៛ រង្វាន់អ្នកប្រមូលដីការកោះ ៣.០០០៛ និង រង្វាន់សាក្សី ២.០០០៛ បូករួម ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០៛ ដែលដើមចោទបានបង់ទុករួចជាស្រេច ។

កាលបើផុតកំនត់ប្ដឹងឧទ្ធរណ៍ បង្គាប់អោយឈ្មោះ សុខ ទៀង សងប្រាក់ ៧.០០០៛ អោយទៅដើមចោទវិញ និង បង្គាប់អោយបង់ពន្ធសមាមាត្រចំនួនមួយភាគរយ លើតម្លៃដីទំហំ ១០ម គុណ ១,៣ម ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ សុខ ទៀង ចុះថ្ងៃទី០១.១២.៨៧ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃ សាលក្រមទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍ លេខ៨៥ ចុះថ្ងៃទី ១០.៣.៨៨ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០១.១២.៨៧ របស់ដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ សុខ ទៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោល ដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១២៣ "ក" ចុះថ្ងៃទី ១៥.១០.៨៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣-សំរេចការយកប្រាក់ប្រដាប់ក្តី នៅជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺ ពន្ធតាំង និង ពន្ធចុះបញ្ជីក្តី ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីការកោះ ៥.០០០៛ និង លើអាជ្ញាធរតុលាការ ៥.០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី ។

សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៨៧ ចុះថ្ងៃទី ៣០.៤.៨៨ របស់ឈ្មោះ សុខ ទៀង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ០៩.៦.៨៨ របស់ឈ្មោះ សុខ ទៀង ។

បានឃើញសារណាតបចុះថ្ងៃទី ១១.៧.៨៨ របស់ឈ្មោះ នូវថារ៉ា ។

បានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។

សាលដីការបស់សាលាឧទ្ធរណ៍ បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ ទៀង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ឆ្លើយថា :

-នៅឆ្នាំ ១៩៨៧ ខ្លួនបានទិញផ្ទះ និង ដី គេ ចំណែកដើមចោទមកនៅក្រោយខ្លួន គឺនៅឆ្នាំ ១៩៨៨ ដល់ឆ្នាំ ១៩៨៩ ខ្លួនបានសុំគាត់ជួសជុលជញ្ជាំងផ្ទះ ហើយអោយគាត់ដាក់ម៉ូតូដោយយកតម្លៃ ក្នុង១ខែ ៣.០០០រៀល ដល់ពេលខ្លួនសុំគាត់ឡើងថ្លៃ៥ដុល្លាក្នុង១ខែ គាត់ប្តឹងខ្លួន ។ ខ្លួនសុំមិនអោយដើមចោទចេញចូលក្នុងផ្ទះខ្លួនទៀតទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ នួន ថារ៉ា ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ឆ្លើយថា :

- ខ្លួនបានគ្រប់គ្រង និង កាន់កាប់ដីនៅក្រោមជណ្តើរនេះដោយស្ងប់ស្ងាត់ តាំងពីឆ្នាំ ១៩៨៧ ដល់ឆ្នាំ ១៩៩២ ឈ្មោះ សុខ ទៀង បានសុំទុកខ្លួនពង្រីកជញ្ជាំងផ្ទះដោយសន្យា អោយខ្លួនដាក់ម៉ូតូ ឥតគិតថ្លៃ ហើយអោយខ្លួនចេញចូលក្នុងផ្ទះនេះ នៅពេលណាផ្លូវរបស់ផ្ទះខ្លួនស្ទះ ទើបខ្លួនក៏ឯកភាពអោយគាត់ពង្រីកផ្ទះ នៅពេលពង្រីកផ្ទះ ហើយ គាត់ឱយខ្លួនដាក់ម៉ូតូក្នុងរយៈពេល១ឆ្នាំ ក្រោយមកគាត់ទារថ្លៃឈ្នួលដាក់ម៉ូតូ ក្នុង១ខែ ៣.០០០រៀល រហូតដល់ ១០ ដុល្លាក្នុង១ខែ ហើយមិនអោយខ្លួនចេញចូលក្នុងផ្ទះទៀតនៅពេលផ្លូវផ្ទះរបស់ខ្លួនស្ទះ ។ ខ្លួនសំណូមពរ សុំអោយឈ្មោះ សុខ ទៀង រក្សាភាពដើមនៃដីនេះវិញ និង សុំកាន់កាប់ដីនេះវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយដោះសារ របស់គូភាគី

-ក្រោយពីបាន ពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-ឃើញថា បណ្តឹងសាទុក្ខលេខ ៨៧ ចុះថ្ងៃទី ៣០.៤.៩៨ របស់អ្នកស្រី សុខ ទៀង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី ។

-ឃើញថា ទីតាំងដីទំនាស់ស្ថិតនៅក្រោមជណ្តើរផ្ទះលេខ ៥៤៧ អឺ០ ក្រុម២៤ ផ្លូវលេខ ១២៨ សង្កាត់ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ជាប្រភេទដី ទុកសំរាប់ជាសេវភាពរួមនៃផ្ទះលេខ ៥៤៧អឺ០ និង អឺ១ ដែលតាមលិខិតរបស់ការិយាល័យសំណង់ខ័ណ្ឌទួលគោក បញ្ជាក់ថា គួរអោយម្ចាស់ផ្ទះលេខ ៥៤៧អឺ០ រុះរើជញ្ជាំងនេះចេញហើយរក្សាទីតាំងនេះ តាមសភាពដើមវិញ ។

-ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ចុងចម្លើយពិតជាបានពង្រីក ជញ្ជាំងផ្ទះរបស់ខ្លួន ចូលដីជើងផ្ទះ ដោយពុំមានការអនុញ្ញាតិ ពីអង្គភាពមានសមត្ថកិច្ចប្រាកដមែន ។

-ឃើញថា ខ្លឹមសារ នៃសារណា ចុះថ្ងៃទី ០៩.៦.៩៨ របស់អ្នកស្រីសុខ ទៀង ដែលបានលើកឡើងមកនេះ សុទ្ធតែជារឿងនៃ អង្គហេតុ ដែលតុលាការថ្នាក់ក្រោម បានពិចារណា រួចហើយ ។

-ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៨៥ ចុះថ្ងៃទី ១០.៣.៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ ទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខ គូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៨៧ ចុះថ្ងៃទី ៣០.៤.៩៨ របស់អ្នកស្រី សុខ ទៀង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុស និង គតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៨៥ ចុះថ្ងៃទី ១០.៣.៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងស្រុង ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលអ្នកស្រី សុខ ទៀង បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីការពីប្រាក់ .

-ចំណាយលើកិច្ចប្រែសដីកាពោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

បង្គាប់អោយចុងចម្លើយ បង់ពន្ធសមាមាត្រ តាមការកំណត់ របស់ តុលាការក្រុងភ្នំពេញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៨ ។